**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចព្រមព្រៀង
## រវាង
## រោងចក្រ អេវ៉ាយស៊ី ហ្គាមិន ហ្វេកធើរី ខ.ក
## និង
## តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំរោងចក្រ អេវ៉ាយស៊ី ហ្គាមិន ហ្វេកធើរី ខ.ក
## ស្តីពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃសុក្រ ១២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង០៩ និង០០នាទីព្រឹក នៅក្នុងរោងចក្រ អេវ៉ាយស៊ី ហ្គាមិន ហ្វេកធើរី ខ.ក មានកិច្ចប្រជុំមួយរវាង តំណាងក្រុមហ៊ុន តំណាងកម្មករនិយោជិត និងសហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ៖ លោកនាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា៖ ដោយសារតែក្រុមហ៊ុនយើងមិនមានការបញ្ជាទិញគ្រប់គ្រាន់សម្រាប់ផលិត ដែលមិនអាចឱ្យចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន។ ទើបក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតសរុប ចំនួន៥៥៨នាក់ ស្រីចំនួន៤២៤នាក់ ក្នុងចំណោមកម្មករនិយោជិតសរុប ចំនួន៥៥៨នាក់ ស្រីចំនួន៤២៤នាក់ រយៈពេលចំនួន០២ខែ គិតចាប់ពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ។ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ៖ កម្មករនិយោជិតបានឯកភាពទទួលយកការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ចំនួន៤០ដុល្លារ (សែសិបដុល្លារអាមេរិកគត់) ក្នុង១ខែ សម្រាប់កម្មករនិយោជិតម្នាក់ៗ ហើយបើកឱ្យកម្មករនិយោជិតនៅថ្ងៃទី១០ នៃខែបន្ទាប់ ។

អង្គប្រជុំបានបញ្ចប់នូវវេលាម៉ោង១០ និង០០នាទី នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងមានការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និងសហការណ៍គ្នាយ៉ាងល្អ ។

ថ្ងៃសុក្រ ១២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
កណ្តាល,ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣

**តំណាងកម្មករ និងតំណាងសហជីព** | **នាយកក្រុមហ៊ុន**
**ស្នាមមេដៃ**

AYC GARMENT FACTORY CO., LTD
KINGDOM OF CAMBODIA

Scanned with CamScanner